**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សារលិខិតជូនពរ

**សូមគោរពជូន**
**សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

ក្នុងឱកាសចម្រើនជន្មាយុរបស់ **សម្តេចពិជ័យសេនា** នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២២នេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ មានក្តីសោមនស្សរីករាយឥតឧបមា សូមសម្តែងនូវការចូលរួមអបអរសាទរ និងគោរពជូនពរចំពោះ **សម្តេច** សូមសមប្រកបដោយ សុខភាពល្អបរិបូរណ៍ ពលានុភាពខ្លាំងក្លា បញ្ញាញាណវាងវៃ និងមានជន្មាយុយឺនយូរ។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវការកោតសរសើរដោយស្មោះអស់ពីដួងចិត្ត ជូនចំពោះ **សម្តេច** ដែលបានខិតខំបំពេញភារកិច្ចអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ជាប្រមុខ ដើម្បីកសាងដឹកនាំប្រទេសជាតិឱ្យមានសន្តិភាព និងការអភិវឌ្ឍគ្រប់វិស័យ។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ សូមអនុញ្ញាតគោរពជូនពរ **សម្តេចពិជ័យសេនា និងលោកជំទាវ** ព្រមទាំង **បុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមសមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចពិជ័យសេនា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅនិងខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ សុក្រ ៤ កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៨ខែ តុលា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រុំ សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh